# គំនិតមូលដ្ឋានស្តីពីសិទ្ធិមនុស្ស

## ក. មូលហេតុនៃសិទ្ធិមនុស្ស : ការការពារតំរូវការជាមូលដ្ឋានរបស់មនុស្ស

### ១. "តំរូវការ"ជាមូលដ្ឋានរបស់មនុស្ស:

នៅប្រទេសនីមួយៗមានប្រជាជនច្រើនប្រភេទរស់នៅ :

មានមនុស្សចាស់ និងក្មេង អ្នកមានការសិក្សា និងអនក្ខរជន អ្នកដែលមាននិន្នាការនយោបាយ និង ជំនឿសាសនាផ្សេងគ្នា អ្នកដែលមានទ្រព្យសម្បត្តិ និងគ្មានទ្រព្យសម្បត្តិ បុរស និងស្ត្រី អ្នកដែលប្រព្រឹត្ត បទឧក្រិដ្ឋ និងអ្នកដែលមិនបានប្រព្រឹត្តបទឧក្រិដ្ឋ អ្នកដែលមានជាតិសាសន៍ផ្សេងគ្នា និងអំបូរជនជាតិ ភាគតិច ។
ឧទាហរណ៍ : នៅប្រទេសកម្ពុជាក៏មានប្រជាជនថៃ និងវៀតណាមរស់នៅដែរ ។

ទោះបីជាពួកគេទាំងអស់ខុសៗគ្នា តែពួកគេមានចំណុចរួមមួយ:

ពួកគេគឺជាមនុស្ស ហើយមនុស្សម្នាក់ៗមាន :

- រូបរាងកាយ
- ស្មារតី,ព្រលឹង
- ហើយរស់នៅជាក្រុមក្នុងចំនោមមនុស្សដទៃទៀត ។

ហេតុដូច្នេះមនុស្សទាំងអស់មានតំរូវការជាមូលដ្ឋានដូចៗគ្នា ៖

♦ **ជីវិតខាងរូបកាយ (រូបរាងកាយ) ៖**

- បូរណភាពរូបកាយដែលមិនត្រូវប៉ះពាល់៖ មិនត្រូវបានសំលាប់ រឺធ្វើទារុណកម្ម
- ចលនាដោយសេរីនៃរូបកាយ ៖ - ការធ្វើដំណើរ និងតាំងលំនៅ
  - គ្មានការចាប់ខ្លួនតាមទំនើងចិត្ត
  - គ្មានទាសភាព
- មធ្យោបាយចិញ្ចឹមជីវិត៖
  - មុខរបរ ៖ -ជ្រើសរើស និងបំពេញការងារ ធ្វើការនៅក្នុងស្ថានភាពត្រឹមត្រូវ
  - កម្មសិទ្ធិ ៖ -ទទួលបាននូវផលការងារ៖ គ្មានការដកហូតយកដីតាមទំនើងចិត្ត
    -ទទួលចំណែកទ្រព្យសម្បត្តិសាធារណៈដោយយុត្តិធម៌
    -មានបរិយាកាសមានសុវត្ថិភាព
  - សន្តិសុខសង្គម៖ សំរាប់មនុស្សចាស់ ជនពិការ និងក្មេង ។
- សុខភាព

♦ **ជីវិតខាងផ្លូវចិត្ត ៖**

- ជំនឿនយោបាយ ជំនឿសាសនា
- គ្រួសារ ៖ ទំនាក់ទំនងរវាងមនុស្ស
- ការអប់រំ
- វិស័យឯកជន ៖ គ្មានការឆែកឆេរផ្ទះតាមទំនើងចិត្ត ។

♦ **ការរស់នៅជាក្រុម ៖**

- ការទំនាក់ទំនង ៖ សេរីភាពក្នុងការបញ្ចេញមតិយោបល់ និង សេរីភាពក្នុងការទទួលពតិមាន
- សមាគម ៖ សេរីភាពក្នុងការចូលរួមប្រជុំ សេរីភាពក្នុងការបង្កើតជាក្រុម ឬសមាគម
- ការចូលរួម ៖ ការបោះឆ្នោត ទទួលបានការជ្រើសរើសឱ្យកាន់មុខតំណែងមួយ

# តំរូវការជាមូលដ្ឋាននៃមនុស្សម្នាក់ៗ



## ២. ការមិនគោរពតំរូវការមូលដ្ឋានរបស់បុគ្គលផ្សេងទៀត

ក្នុងករណីជាច្រើនតំរូវការជាមូលដ្ឋាននៃបុគ្គលផ្សេងទៀតមិនត្រូវបានគោរពៈ

ឧទាហរណ៍:

- អ្នកដែលមាននិន្នាការនយោបាយ ឬជំនឿសាសនាខុសគ្នាត្រូវបានបង្ក្រាប ចាប់ខ្លួន រឺសំលាប់ ។
- ស្ត្រីត្រូវទទួលការវាយដំពីសហព័ទ្ធ (ស្វាមី) ។
- កុមារត្រូវលក់ដោយឈ្មួញកណ្តាល ។
- ជនដែលមានសញ្ជាតិ ឬអំបូរជនជាតិភាគតិចផ្សេងគ្នា ត្រូវបានបណ្តេញចេញ ប្លន់ ឬសំលាប់ ។
- ឧក្រិដ្ឋជនត្រូវបានធ្វើទារុណកម្ម និងសំលាប់ ។
- ឧក្រិដ្ឋជនលួចទ្រព្យសម្បត្តិ ។
- ប្រជាជនក្រីក្រត្រូវបានគេដកហូតយកដីដោយរំលោភបំពាន ។

តើមានមូលហេតុអ្វីខ្លះចំពោះការមិនគោរពនេះ?

- ការបែងចែករវាងមនុស្សដែលមានតំលៃ និងមនុស្សដែលគ្មានតំលៃ:
  មនុស្សខ្លះត្រូវបានគេមើលឃើញថាគ្មានតំលៃដូចគេទេ ។ ការបដិសេធនឹតំរូវការជាមូលដ្ឋានរបស់ពួកគេធ្វើឱ្យអ្នកជិះជាន់គេមានអារម្មណ៍មានប្រៀប និង ខ្លាំង ។
  ឧទាហរណ៍: បុរសវាយស្ត្រី ។ ជនជាតិថៃ ឬជនជាតិវៀតណាមត្រូវបានគេវាយប្រហារ ។
- ឬពួកគេត្រូវបានគេមើលឃើញថាជាអ្នកធ្វើខុស ដែលជីវភាពរស់នៅរបស់ពួកគេមិនស្របនឹងរូបភាពនៃពិភពលោកដ៏ល្អឥតខ្ចោះមួយ ។
  ការគាបសង្កត់ ឬកំចាត់ ឬបណ្តេញពួកគេចេញពីប្រទេសមួយ វាហាក់ដូចជាធ្វើឱ្យពិភពលោកមានលក្ខណៈល្អឥតខ្ចោះ ។
  ឧទាហរណ៍: ចោរត្រូវបានសំលាប់ដោយហ្វូងមនុស្ស ។ ប៉ុលពតចង់ធ្វើ "បដិវត្តន៍" លើប្រជាជនកម្ពុជា ដើម្បីឱ្យរួចផុតពីពួកមូលធន ដូច្នេះ "អង្គការ" របស់គាត់បានសំលាប់ទាំងអស់អ្នកដែលគាត់មើលទៅហាក់ដូចជាមានគំនិតផ្ទុយពីគាត់ (បញ្ញាវន្ត អ្នកទីក្រុង)
- ដំណោះស្រាយជម្លោះដោយហិង្សាហាក់ដូចជាងាយស្រួល ហើយបង្ហាញលទ្ធផលឆាប់រហ័សនៅពេលតំរូវការផ្ទាល់ខ្លួនត្រូវបានបដិសេធ មនុស្សមានទំនោរបដិសេធតំរូវការរបស់អ្នកដទៃផងដែរ ។
  ឧទាហរណ៍: នៅឆ្នាំ ២០០៣ ប៉ូលីសថៃបានសំលាប់អ្នកញៀនអាភៀនជាង ២០០០នាក់ ដើម្បីដោះស្រាយបញ្ហាគ្រឿងញៀន ។

## ៣. ការឆ្លើយតបទៅនឹងការមិនគោរពដល់តំរូវការនៃសិទ្ធិមនុស្សៈ

គំនិតរបស់សិទ្ធិមនុស្សផ្តល់នូវចំលើយ ៣ ដូចខាងក្រោមដើម្បីឆ្លើយតបនឹងមូលហេតុនៃការមិនគោរពដែលបានបញ្ជាក់នៅខាងលើ :

### ៣.១. គ្មានទេពិភពលោកឥតខ្ចោះ តែមាន **សេរីភាព** :

"តំរូវការ" ជាមូលដ្ឋានគ្រឹះរបស់មនុស្សត្រូវតែការពារដោយ "សិទ្ធិមនុស្ស" : នៅពេលដែលតំរូវការជាមូលដ្ឋានរបស់មនុស្សត្រូវបានគោរព ហើយត្រូវបានបំពេញ គេអាចរស់នៅបានដោយសេរីនៅក្នុងសង្គម និងអាចអភិវឌ្ឍន៍សមត្ថភាពផ្ទាល់ខ្លួនរបស់គេ និងមានគំនិតច្នៃប្រឌិតក្នុងផ្លូវល្អ ។ ដូច្នេះ មនុស្សម្នាក់ត្រូវតែមានសិទ្ធិទាមទារនូវការគោរពដល់តំរូវការជាមូលដ្ឋានរបស់ខ្លួនពីជនានុជនទាំងឡាយ ។ កត្តានេះ មិនអាចបង្កើតអោយមានពិភពលោកមួយល្អឥតខ្ចោះនោះទេ តែឱ្យមានពិភពលោកមួយដែលមាន យុត្តិធម៌ សន្តិភាព និងស្នេហភាព ។

### ៣.២. គ្មានការបែងចែករវាងមនុស្ស តែមាន **តំលៃស្មើគ្នា** :

មនុស្សគ្រប់រូបខុសៗគ្នា តែមនុស្សម្នាក់ៗមានតំរូវការដូចៗគ្នា។ ការការពារតំរូវការ និងការផ្តល់នូវសេរីភាព មិនត្រូវធ្វើចំពោះតែមនុស្សមួយចំនួននោះទេ មនុស្សគ្រប់រូបត្រូវតែទទួលបាននូវតំលៃ ស្មើគ្នា មានន័យថាមនុស្សមានតំលៃថ្លៃថ្លាណាស់ដោយគ្មានលក្ខខណ្ឌ ។ មិនគួរមាននរណាម្នាក់ត្រូវបានកំចាត់ចេញពីសង្គមនោះទេ ។

### ៣.៣. ដំណោះស្រាយជម្លោះដោយអហិង្សា តែមាន**វិធានច្បាប់** :

នៅក្នុងសង្គមមនុស្ស ជំលោះរវាងសេរីភាពស្មើៗគ្នានៃមនុស្សម្នាក់ៗ មិនត្រូវដោះស្រាយដោយហិង្សា ឬការកំចាត់មនុស្សចេញនោះទេ ។ វិវាទ ត្រូវបានដោះស្រាយដោយច្បាប់ ។ គោលបំណងតែមួយគត់របស់ច្បាប់គឺ ការពារ និងធ្វើឱ្យសិទ្ធិមនុស្សមានតុល្យភាព ។ មនុស្សបង្កើតរដ្ឋ មានរួមទាំងស្ថាប័នទាំងអស់ ក្នុងគោលបំណងតែមួយគត់គឺដើម្បីការពារ និងរក្សាតុល្យភាពនៃសិទ្ធិមនុស្ស ។ រដ្ឋត្រូវបំរើប្រជាជន ។

ជនជាតិបារាំង[២០] ហៅគោលការណ៍ទាំង ៣ នេះថា: **សេរីភាព សមភាព ភាតរភាព** (Leberté, Egalité and Fraternité) ។

> សេចក្តីថ្លែងការណ៍របស់បារាំងស្តីពីសិទ្ធិមនុស្សនៅឆ្នាំ១៧៨៩ :
>
> **មាត្រា១:** មនុស្សកើតមកត្រូវមានសេរីភាព និងសិទ្ធិស្មើៗគ្នា ។
> **មាត្រា២:** គោលបំនងរបស់គ្រប់សមាគមនយោបាយគឺការការពាររក្សានូវសិទ្ធិពីធម្មជាតិរបស់មនុស្ស
> **មាត្រា៤:** សេរីភាពគឺមនុស្សអាចធ្វើអ្វីៗបានទាំងអស់ កុំឱ្យតែប៉ះពាល់ដល់អ្នកដទៃៈ ហេតុដូច្នេះ ការប្រើប្រាស់សិទ្ធិពីធម្មជាតិរបស់មនុស្សម្នាក់ៗមិនមានព្រំដែនកំណត់អ្វីក្រៅពីធ្វើឱ្យ សមាជិកដទៃទៀតនៃសង្គមបានទទួលនូវសិទ្ធិដូចគ្នានេះដែរ ។ មានតែច្បាប់ទេដែលអាចកំណត់ព្រំដែនទាំងនោះបាន ។

[២០] សូមមើល www.elysee.fr/ang/instit/text1_.htm

# ៤. ទស្សនវិជ្ជាដើមនៃសិទ្ធិមនុស្ស

## ៤.១. គ្មានមនុស្សល្អឥតខ្ចោះ

មនុស្សម្នាក់តែងមានការខុសឆ្គង ។ កំហុស គឺមនុស្ស ។ ជីវិតមិនដែលល្អឥតខ្ចោះទេ ។ ដូច្នេះគ្មានគំនិតនយោបាយ ឬសាសនារបស់ក្រុមមនុស្សណាមួយអាចអះអាងថាពិតជាត្រឹមត្រូវ ហើយគ្មានជនណាម្នាក់អាចអះអាងថាខ្លួនឯងល្អជាងគេ ឬមានតំលៃជាងគេនោះទេ ។ អ្នកណាអះអាង ដូច្នេះ គឺជាមនុស្សខ្វាក់ ហើយមើលមិនឃើញពីកំហុសផ្ទាល់ខ្លួនឡើយ ។

ឧទាហរណ៍: អ្នកណាដែលចង់បង្កើតពិភពលោកមួយឥតខ្ចោះ មិនបានគិតដល់ឧត្តមគតិនេះទេ ។ ពួកគេបានបង្កើតឋាននរកនៅលើផែនដីដូចជា ប៉ុលពត ឬជនហ្វាស៊ីសអាល្លឺម៉ង់ ឬហ្វូងមហាជនដែលសំលាប់ចោរ ។

## ៤.២. មនុស្សម្នាក់ៗមានតំលៃខ្លាំងណាស់

ដោយសារមនុស្សជារបស់ទោល ដូច្នេះវាមិនអាចមានអ្វីមកជំនួសបានឡើយ ។ ស្ថានភាពរស់នៅជាពិសេសរបស់គេធ្វើឱ្យស្ថានភាពរស់នៅផ្សេងទៀតមានភាពសំបូរបែប ធ្វើឱ្យប្រព័ន្ធជីវសាស្រ្ត និងសង្គមកាន់តែរឹងមាំឡើង ។ ភាពខុសគ្នារបស់មនុស្ស ធ្វើអោយជីវិតកាន់តែមានពិណស្រស់បំព្រងឡើង ។ គេមានគំនិតផ្សេងៗគ្នានៅក្នុងការដោះស្រាយបញ្ហា ។ គ្មាននរណាម្នាក់អាចរស់នៅតែឯកឯង និងខ្វះបទពិសោធន៍ផ្សេងៗគ្នាទាំងនោះឡើយ ។ ពាក្យខ្មែរមួយឃ្លាថា "នៅពេលជួបមនុស្ស ៣នាក់ដែលយើងមិនស្គាល់ ម្នាក់ក្នុងចំនោមពួកគេគឺជាគ្រូរបស់យើង" ។

ឧទាហរណ៍: នៅពេលទទួលការវាយប្រហារដោយហ្វូងមនុស្ស ជនជាតិថៃ ឬជនជាតិវៀតណាម បុរស ស្ត្រី ឬកុមារ ក៏មានអារម្មណ៍ដូចគ្នានឹងជនជាតិខ្មែរ បុរស ស្ត្រី ឬកុមារដែលទទួលរងការវាយប្រហារដែរ

## ៤.៣. ការមិនគោរពដល់តំរូវការរបស់អ្នកដទៃ និងដំណោះស្រាយវិវាទដោយហិង្សា តែងតែនាំមកនូវទុក្ខវេទនា អយុត្តិធម៌ អស្ថេរភាព ការឈឺចាប់ និងភាពភ័យខ្លាច ។

ការដោះស្រាយវិវាទដោយហិង្សា មិនបានស្វែងរកនូវតុល្យភាពនៃសិទ្ធិទេ តែខិតខំបំបាត់សិទ្ធិរបស់អ្នកដទៃ ។ វានាំឱ្យមានការតស៊ូកាន់តែសាហាវឡើង ។ បើសិនជានៅក្នុងសង្គម តំរូវការបុគ្គលជាមូលដ្ឋានរបស់មនុស្សម្នាក់ៗមិនត្រូវបានគោរពអាចនាំអោយមានអំពើអយុត្តិធម៌ ការសងសឹក ការវាយបកដោយប្រើហិង្សា អស្ថេរភាព ។

ឧទាហរណ៍: នៅពេលដែលភាពលំបាករបស់ប្រជាជនមិនត្រូវបានគេយកចិត្តទុកដាក់ ឬទទួលការប្រមាថមើលងាយ ឬតំរូវការរបស់ពួកគេត្រូវបានបដិសេធ គេអាចក្លាយជាមនុស្សឃោឃៅ ។ ដូចជាករណីចោរ គាត់អាចលួចត្រឹមតែចំណីរអាហារ ដើម្បីចំអែតក្រពះ នៅពេលក្រោយគាត់នឹងអាចប្រើប្រាស់អាវុធដើម្បីប្លន់ ដើម្បីជៀសផុតពីការស្លាប់ ។

ឧត្តមគតិនេះ វាក៏ជាផ្នែកមួយនៃ**ព្រះពុទ្ធសាសនា និងទស្សនវិជ្ជា**ផងដែរ:

"...នេះមិនត្រឹមតែជាសមភាពរវាងពុទ្ធសាសនា និងប្រជាធិបតេយ្យទេ តែវាមានឫសគល់លើទស្សនៈរួមនៃសមភាព និងសក្តានុពលភាពរបស់មនុស្សគ្រប់រូប ។ ... ការស្វែងរកការបំពេញបំណងផ្ទាល់ខ្លួនលើគំនរទុក្ខអ្នកដទៃអាចនាំឱ្យមានភាពវឹកវរ និងអនាធិបតេយ្យ" ។ (មើល: ដាឡៃឡាម៉ា ពុទ្ធសាសនា ក្នុងកាសែតប្រជាធិបតេយ្យ ឆ្នាំ១៩៩៩ ទំព័រទី៣ មាននៅក្នុងបណ្ណាល័យឱមរាដ្ឋសាឌីនៃវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ) ។

ព្រហ្មវិហារធម៌ទាំងបួនរបស់ព្រះពុទ្ធដើម្បីប្រតិបត្តិឱ្យមានចិត្តបរិសុទ្ធ បង្រួមឧត្តមគតិនេះឱ្យទៅជាផ្លូវដូចខាងក្រោម:

មេត្តា: ស្រលាញ់រាប់អានគ្នាដោយស្មោះទៅវិញទៅមក ។
ករុណា: អាណិតអាសូរ និងអ្នកក្រលំបាក ។
មុទិតា: ត្រេកអរចំពោះក្តីសុខចំរើនរបស់អ្នកដទៃ ។
ឧបេក្ខា: ធ្វើជាកណ្តាល និងគិតឱ្យបានហ្មត់ចត់មុននឹងធ្វើអ្វីមួយ ។

## ៥. អត្ថបទច្បាប់ដែលបញ្ជាក់ពីគំនិតសិទ្ធិមនុស្សទាំងនេះ :

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ១៩៩៣ (CC) បុព្វកថា:

យើងប្រជារាស្ត្រខ្មែរ... បានទទួលរងនូវទុក្ខសោក និងការបំផ្លិចបំផ្លាញវិនាសអន្តរាយដ៏យូរលង់ និងសោកនាដកម្ម ក្នុងអំឡុងជាងពីរទសវត្សចុងក្រោយនេះ បានភ្ញាក់រលឹក ក្រោកឈរឡើងជាមួយការប្តេជ្ញាដ៏មោះមុត ... កសាងប្រទេសជាតិឱ្យទៅជា "កោះសន្តិភាព" ឡើងវិញ ដោយផ្អែកលើប្រព័ន្ធប្រជាធិបតេយ្យសេរីពហុបក្ស ធានាសិទ្ធិមនុស្ស គោរពច្បាប់ ទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិឱ្យបានឈានឡើងរីកចំរើនលូតលាស់ សម្បូររុងរឿង ជានិច្ចនិរន្តរ៍ ...។

សេចក្តីថ្លែងការណ៍ជាសកលស្តីពីសិទ្ធិមនុស្ស ១៩៤៨ (UDHR) បុព្វកថា:

" ... ដោយយល់ឃើញថា ការទទួលស្គាល់នូវសេចក្តីថ្លៃថ្នូររបស់មនុស្សដែលមានតាំងពីកំណើត និងសិទ្ធិស្មើភាពគ្នា និងដែលមិនអាចដកហូតបានរបស់មនុស្សគ្រប់រូប គឺជាគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាព ក្នុងពិភពលោក ។

ដោយយល់ឃើញថា ការមិនទទួលស្គាល់ និងការប្រមាថមើលងាយសិទ្ធិមនុស្ស បាននាំអោយកើតមាននូវអំពើព្រៃផ្សៃសាហាវយង់ឃ្នង ដែលប៉ះពាល់យ៉ាងខ្លាំងដល់មនសិការមនុស្សជាតិ ..."

កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ១៩៦៦ (ICCPR) បុព្វកថា:

ដោយពិនិត្យឃើញថា ... ការទទួលស្គាល់សេចក្តីថ្លៃថ្នូរផ្ទាល់ខ្លួន សមភាព និងសិទ្ធិដែលមិនអាចបដិសេធបានរបស់សមាជិកនៃគ្រួសារមនុស្សជាតិជាមូលដ្ឋានគ្រឹះនៃសេរីភាព យុត្តិធម៌ និងសន្តិភាពនៅលើពិភពលោក ... យោងទៅតាមសេក្តីថ្លែងការណ៍ជាសកលស្តីអំពីសិទ្ធិមនុស្ស ឧត្តមគតិស្តីពីការរស់នៅដោយសេរី មានសិទ្ធិពលរដ្ឋ មានសិទ្ធិនយោបាយ និងមានសិទ្ធិសេរីភាពប្រាសចាកពីការភ័យខ្លាច និងការតាមចាប់ខ្លួន អាចសំរេចទៅបានលុះត្រាតែមានការបង្កលក្ខណៈឱ្យមនុស្សគ្រប់រូបអាចទទួលបាននូវសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ព្រមទាំងសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ផងដែរ ...

## ៦. សមភាពដែលធានាដោយច្បាប់ :

### ៦.១. បញ្ញត្តិជាទូទៅ :

មាត្រា៣១ CC :

ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ ។

មាត្រា២៦ ICCPR :

នៅចំពោះមុខច្បាប់ មនុស្សគ្រប់ៗរូបមានសិទ្ធិស្មើៗគ្នា ហើយក៏មានសិទ្ធិទទួលកិច្ចការពារអំពីច្បាប់ស្មើគ្នាដោយគ្មានការរើសអើង ។ នៅក្នុងគំនិតនេះ ច្បាប់ហាមមិនអោយមានការប្រកាន់ពូជសាសន៍ហើយ ត្រូវធានាឱ្យបុគ្គលគ្រប់រូបទទួលនូវការការពារស្មើគ្នា និងប្រកបដោយប្រសិទ្ធិភាព ប្រឆាំងនឹងការរើសអើងពូជសាសន៍ ពិណសំបុរ ភេទ សាសនា ភាសា ជំហរនយោបាយ មតិនានា កំណើតជាតិ ឬសង្គម ឋានៈ វណ្ណៈ ឬស្ថានភាពផ្សេងៗទៀតឡើយ ។

មាត្រា ១ UDHR ( ១៩៤៨):

មនុស្សទាំងអស់កើតមកមានសេចក្តីថ្លៃថ្នូរ និងសិទ្ធិស្មើៗគ្នា ។ មនុស្សគ្រប់រូប សុទ្ធតែមានវិចារណញ្ញាណ និងសតិសម្បជញ្ញៈ ហើយគោរពគ្នាទៅវិញទៅមក ក្នុងស្មារតីរាប់អានគ្នាជាបងប្អូន។

មាត្រា ២ UDHR ( ១៩៤៨):

មនុស្សគ្រប់រូបមានសិទ្ធិ និងសេរីភាពគ្រប់បែបយ៉ាងទាំងអស់ដូចមានចែងក្នុងសេចក្តីប្រកាសនេះ ដោយគ្មានការបែងចែកជាតិសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗទៀត ប្រភពកំណើត ឬសង្គម ទ្រព្យសម្បត្តិ កំណើត ឬស្ថានភាព ផ្សេងទៀត ។

## ៦.២. បទបញ្ញត្តិពិសេសដើម្បីការពារដល់ក្រុមមនុស្សទន់ខ្សោយៈ

| **សិទ្ធិនារី** | **សិទ្ធិកុមារ** | **សិទ្ធិជនជាតិភាគតិច** | **ពលករ** |
| --- | --- | --- | --- |
| មាត្រា ៣១,៣៦ I II,៤៥ និង ៤៦ CC | មាត្រា ៣១ ៤៨ CC | មាត្រា២៧ ICCPR | មាត្រា៣៦ II CC |
| អនុសញ្ញា ប្រឆាំងនឹងការរើសអើងស្ត្រី (ឆ្នាំ១៩៧៦) | អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ (ឆ្នាំ១៩៨៩) | អនុសញ្ញាស្តីពីការប្រឆាំងនឹងការរើសអើងពូជសាសន៍ CERD(ឆ្នាំ១៩៦៥) | ប្រាក់បៀវត្តន៍ដូចគ្នាចំពោះការងារដូចគ្នា |

## ៧. គោលការណ៍ក្នុងទំរង់រូបភាពខ្លីៗ


បទពិសោធន៍ប្រវត្តិសាស្ត្រ
សិទ្ធិមនុស្ស
ការពារ
សិទ្ធិនៃ
មនុស្សម្នាក់
មនុស្សនៅក្នុងក្រុមមួយ
សិទ្ធិពលរដ្ឋ
- រូបរាងកាយ
- គ្រួសារ
- ស្មារតី
- ទីលំនៅ
- កម្មសិទ្ធិ
- ការប្រកបអាជីវកម្ម
- ជំរក ការដើរហើរ
សិទ្ធិសង្គម និង
សិទ្ធិវប្បធម៌
- សុខភាព
- ការអប់រំ
- ការងារ
សមភាព
- សិទ្ធិរបស់ជនជាតិភាគតិច
សិទ្ធិនយោបាយ
- ទំនាក់ទំនង
- សមាគម
- ការចូលរួម
សិទ្ធិទាំងនេះ
ធានានូវ
សេរីភាព
សេរីភាពនៃ
បុគ្គល "ក"
សមភាព
សេរីភាពនៃ
បុគ្គល "ខ"
វិវាទ
នៃសេរីភាពស្មើគ្នា
ដោះស្រាយ
ដោយ
ច្បាប់
( ការពារឱ្យមានតុល្យភាពរវាងសេរីភាពទាំងពីរ)



## ករណីសិក្សាទី១:

ហ្វូងមនុស្សដែលខឹងសម្បា បានសំលាប់ចោរនៅលើដងផ្លូវនៅក្នុងទីក្រុងភ្នំពេញ ។ ពួកគេកំពុងសើច ។

ក. ចូរសាកល្បងពិចារណាអំពីអ្វីដែលពួកគេគិត និងមានអារម្មណ៍ ។ ចូររៀបរាប់ពីអារម្មណ៍របស់ពួកគេ ។

ខ. ចូរសាកល្បងពិចារណាពីអ្វីដែលជនរងគ្រោះមានអារម្មណ៍ និងបានគិត ។
បើសិនជាអ្នកស្ថិតក្នុងស្ថានភាពជាជនរងគ្រោះវិញ តើអ្នកគួរនិយាយអ្វីដើម្បីការពារខ្លួន ?

គ. ចូរសាកល្បងពិចារណាពីអ្វីដែលម្ចាស់ហាងមានអារម្មណ៍ និងបានគិត បើសិនជាទ្រព្យសម្បត្តិរបស់គាត់ត្រូវបានចោរលួច ។ ចូរអធិប្បាយពីអ្វីដែលគាត់គួរតែនិយាយ ?

## ? សំនួរសិក្សាទី៤

ក. តើសិទ្ធិជាមូលដ្ឋានណាខ្លះដែលពាក់ព័ន្ធនៅក្នុងវិវាទរវាង ម្ចាស់ហាង ចោរ និង ហ្វូងមនុស្សនេះ?

ខ. តើអ្វីទៅជាហេតុផលរបស់ហ្វូងមនុស្សដែលសំលាប់ចោរ?

គ. តើវិវាទនេះត្រូវបានដោះស្រាយយ៉ាងណា?

## ? សំនួរសិក្សាទី៥

ចូរដកស្រង់នូវបទបញ្ញត្តិច្បាប់( មាត្រា) ជាតិ និងអន្តរជាតិ នានាដែលការពារដល់សិទ្ធិស្ត្រីក្នុងការការពាររូបរាងកាយរបស់ពួកគេ ។